**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៤ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការឈប់ទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១ :**

បញ្ឈប់ការទទួលស្គាល់ វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ដែលមានទីតាំងមូលដ្ឋាននៅអគារជាប់ធនាគារកាណាឌីយ៉ា នៅផ្លូវព្រះកុសុមៈនារីរ័ត្ន ឃុំកំពង់ចាម ស្រុកកំពង់ចាម ក្នុងទីរួមខេត្តកំពង់ចាម និង សាខាទាំងអស់ ។

**មាត្រា ២ :**

វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ត្រូវបញ្ឈប់ធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតសិក្សា និង គ្រប់រូបភាព ហើយត្រូវចេញព្រឹត្តិប័ត្រពិន្ទុឱ្យដល់និស្សិតដែលបានសិក្សាស្របច្បាប់នៅក្នុងវិទ្យាស្ថានតាមកម្រិត និង កម្មវិធីសិក្សាតាមការស្នើសុំរបស់និស្សិត ។

**មាត្រា ៣ :**

អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី គ្រឹះស្ថានឧត្តមសិក្សាឯកជន អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យវ៉ាស៊ីតោនឌីស៊ីទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៤២ ខែ ត្រា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ